ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរណែនាំ

# ស្តីពី

## ការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវ័ន្តបុគ្គលបរទេស

Www.KhmerFamous.Com

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**លេខ : ០០២ ដ.ន.ស /អ.ស.ណ/** *ថ្ងៃទី ១០ ខែ០៧ ឆ្នាំ២០០០*

**សារាចរណែនាំ**
**ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និងសាងសង់**
**របស់សហគ្រាស ក្រុមហ៊ុន និង រូបវ័ន្តបុគ្គលបរទេស**

យោងមាត្រាទី ១៩ ត្រង់ផ្នែកទី ៤ នៃច្បាប់ស្តីពី "វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម " ដែលចែងពីក្រុមហ៊ុនបរទេស ដែលមានតែសាខា ឬ ទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា និងយោងតាមប្រកាសលេខ ៧៥ ប្រក.ដ.ន.ស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្មរបស់បណ្តាសហគ្រាស ក្រុមហ៊ុន និងរូបវ័ន្តបុគ្គលបរទេស ដូចតទៅ :

## I. ការកំណត់ទ្រង់ទ្រាយ

សហគ្រាសក្រុមហ៊ុន រូបវ័ន្តបុគ្គលបរទេស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកតាមទ្រង់ទ្រាយអាជីវកម្មដូចតទៅ :

១- សហគ្រាសក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២- សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា

៣- រូបវ័ន្ត បុគ្គលបរទេស សិក្សាគំរោងប្លង់

## II. ការចុះបញ្ជីប្រកបអាជីវកម្ម

*ចំពោះ :*

១- អភិបាលការិយាល័យ តំណាង ឬទីភ្នាក់ងារ និងសាខាក្រុមហ៊ុន ឬអាណត្តិគាហកនៃ សហគ្រាសក្រុមហ៊ុនបរទេសដែលមានការិយាល័យតំណាង ទីភ្នាក់ងារ និងសាខាក្នុងព្រះរាជាណាចក្រកម្ពុជា

២- អភិបាល ឬសមាជិកនៃសហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា

៣- រូបវ័ន្តបុគ្គលបរទេសសិក្សាគំរោងប្លង់

ត្រូវមកបំពេញដោយផ្ទាល់នូវបែបបទសុំចុះឈ្មោះការិយាល័យតំណាងទីភ្នាក់ងារ ឬ សាខាក្រុមហ៊ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងចុះឈ្មោះសហគ្រាស ក្រុមហ៊ុនរូបវ័ន្តបុគ្គលបរទេសសិក្សាគំរោងប្លង់ក្នុងបញ្ជីអាជីវកម្មនៅនាយកដ្ឋានសិក្សាគំរោងប្លង់ចំណុះ អគ្គ-នាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

អភិបាល ឬអាណត្តិគាហក ត្រូវចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីនាយកដ្ឋានសិក្សាគំរោងប្លង់ដើម្បីធានាអះអាងទទួលខុសត្រូវលើរាល់សំណុំលិខិត ដែលខ្លួនបានយកមកតម្កល់ទុក នៅនាយកដ្ឋានសិក្សាគំរោងប្លង់ថាពិតជាគ្រប់គ្រាន់ និងត្រឹមត្រូវមិនមានក្លែងបន្លំលើប្រកាសណាមួយឡើយ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្នុងករណីដែលពិនិត្យឃើញថា លិខិត ឬឯកសារណាមួយនៃសំណុំឯកសារសុំចុះបញ្ជីប្រកបអាជីវកម្មមានភាពមិនច្បាស់លាស់អភិបាលការិយាល័យតំណាង ទីភ្នាក់ងារសាខាក្រុមហ៊ុន ឬប្រធានក្រុមប្រឹក្សាអភិបាលក្រុមហ៊ុន ឬអភិបាលណាម្នាក់ ឬអាណត្តិគាហក ត្រូវមកបំភ្លឺ និងដោះស្រាយទៅតាមករណីនីមួយៗ តាមការកោះអញ្ជើញរបស់ប្រធាននាយកដ្ឋានសិក្សាគំរោងប្លង់។

កាលបើពិនិត្យឃើញថា សំណុំលិខិត និងពត៌មានលក្ខណៈគ្រប់គ្រាន់ ត្រឹមត្រូវតាមការណែនាំ (បញ្ញត្តិ) ហើយនោះមន្ត្រីចុះបញ្ជីនៅនាយកដ្ឋានសិក្សាគំរោងប្លង់ត្រូវធ្វើការចុះបញ្ជីប្រកបអាជីវកម្ម ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រគល់ជូនវិញ្ញាបនប័ត្រ និងប្រកាស ដែលអនុញ្ញាតអោយប្រកបអាជីវកម្ម ដល់អ្នកស្នើសុំក្នុងរយៈពេលយ៉ាងយូរមិនអោយហួសពី ១ ខែ ដោយគិតចាប់ពីថ្ងៃទទួលពាក្យសុំ ដែលមានលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់ ។

### III. ប្រភេទ សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និងសាងសង់

១-១ សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខាក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចសេចក្តីប្រកាស លេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និងសាងសង់ ប៉ុន្តែត្រូវបន្ថែមនូវៈ

- ១- លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគំរោងប្លង់នៃសាមីដើមប្រទេស
- ២- ឯកសារស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស
- ៣- ឯកសារស្តីពីលក្ខន្តិកៈ របស់សហគ្រាស និងក្រុមហ៊ុនរបស់សាមីដើមប្រទេស ។

១-២ សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និងសាងសង់ ត្រង់ចំណុច ក ខ ក្នុងប្រការ ៣ ប៉ុន្តែត្រូវបន្ថែមនូវៈ

- ១- លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់របស់សាមីដើមប្រទេស
- ២- ឯកសារស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស
- ៣- ឯកសារស្តីពីលក្ខន្តិកៈ របស់សហគ្រាស និងក្រុមហ៊ុនរបស់សាមីដើមប្រទេស។

២-១ សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាសក្រុមហ៊ុន បានបែងចែក ជា ៣ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ត្រង់ចំណុច ក ខ គ ក្នុងប្រការ២។

២-២- សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន សាងសង់ បានបែងចែកជា ៣ ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី

នគររូបនីយកម្ម និងសំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ ត្រង់ចំណុច ក ខ គ ក្នុងប្រការ៣។

៣-១- រូបវ័ន្តបុគ្គលបរទេសសិក្សាគំរោងប្លង់ បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ ត្រង់ចំណុច ឃ១ ឃ២ ឃ៣ ឃ៤ ឃ៥ ក្នុងប្រការ២។

**IV ទំរង់បែបបទសុំប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និងសាងសង់**

ទំរង់បែបបទសុំប្រកបអាជីវកម្ម មានលក្ខខ័ណ្ឌកំណត់ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុនសិក្សា គំរោងប្លង់ និងសាងសង់ ប៉ុន្តែចំពោះ

១- នាយកបច្ចេកទេស នាយកគំរោង និងអ្នកបច្ចេកទេសនៃសហគ្រាស ក្រុមហ៊ុនបរទេសដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខា ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសញ្ជាតិ បរទេស ឬខ្មែរ

២- ការអនុវត្តការងារសិក្សាគំរោងប្លង់ និងសាងសង់ត្រូវអនុវត្តតាម លិខិតបទដ្ឋានបច្ចេកទេសរបស់ ព្រះរាជាណាចក្រកម្ពុជា។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន និងមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ និងសុរិយោដី ខេត្ត ក្រុងត្រូវទទួលបន្ទុកអនុវត្តតាម ខ្លឹមសារខាងលើ និងតាមភារកិច្ចរៀង១ខ្លួន ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។